# អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

**សូមគោរពជូន**
**ឯកឧត្តម សាយ ឈុំ**
**អនុប្រធានទី១ ព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា**

តាងនាមថ្នាក់ដឹកនាំ មន្ត្រីរាជការទាំងអស់នៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និង ក្នុងនាមខ្ញុំ និង ភរិយាខ្ញុំ ខ្ញុំមានសេចក្តីក្រៀមក្រំជាអនេកចំពោះការទទួលមរណភាពរបស់ **សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម ប្រធានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា** កាលពីវេលាម៉ោង ១៥៖៤៥នាទី ថ្ងៃច័ន្ទ ទី៨ ខែមិថុនា ឆ្នាំ២០១៥ ក្នុងជន្មាយុ ៨៣ឆ្នាំ ។

ក្នុងឱកាសប្រកបដោយក្តីក្តុកក្តួលរំជួលចិត្តក្រៀមក្រំជាទីបំផុតនេះ ខ្ញុំសូមចូលរួមរំលែកទុក្ខ និង សេចក្តីសោកសង្រេងយ៉ាងក្រៃលែង ពោរពេញដោយសេចក្តីសោកស្តាយ អាលោះអាល័យបំផុតជាមួយថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការ ព្រមទាំងក្រុមគ្រួសារ ចំពោះការបាត់បង់ **សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម** ដែលជា ប្រធានព្រឹទ្ធសភាដ៏ឧត្តុងឧត្តម និងជាមេគ្រួសារ បិតា ជីតា ជីតាទួត ជាទីគោរពស្រឡាញ់ ប្រកបដោយព្រហ្មវិហារធម៌ និង ទឹកចិត្តសណ្តោសប្រណីដ៏ថ្លៃថ្លា ។

**សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម** គឺជាកុលបុត្រខ្មែរ ជាឥស្សរជន និងជាវីរជន ដ៏ឆ្នើមមួយរូប ដែលបានយកអស់កម្លាំងកាយចិត្ត និង ស្មារតីចូលរួមដឹកនាំកម្លាំងតស៊ូរំដោះប្រទេស និង ប្រជាពលរដ្ឋឱ្យរួចផុតពីរបបប្រល័យពូជសាសន៍ ប៉ុល ពត និង បានចូលរួមចំណែកយ៉ាងសកម្មក្នុងការស្តារ និង អភិវឌ្ឍន៍ប្រទេសឱ្យមានការរីកចម្រើនលើគ្រប់វិស័យរហូតដល់បច្ចុប្បន្ន ។ សម្តេចបានរួមចំណែកយ៉ាងសំខាន់ក្នុងការកសាងសន្តិភាព និង ស្ថិរភាពនយោបាយសម្រាប់ជាតិមាតុភូមិយើង ជាពិសេសសម្តេចបានបំពេញបេសកកម្មយ៉ាងថ្លៃថ្លា ប្រកបដោយស្មារតីស្នេហាជាតិ ក្នុងការដឹកនាំព្រឹទ្ធសភា ដែលជាស្ថាប័ននីតិបញ្ញត្តិកំពូលរបស់ជាតិ ហើយតាមរយៈបេសកកម្មនេះ បានរួមចំណែកក្នុងការពង្រឹងនីតិរដ្ឋ លទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស ការគោរពសិទ្ធិមនុស្ស ការកែទម្រង់រដ្ឋស៊ីជម្រៅលើគ្រប់វិស័យ និងការលើកកម្ពស់សុខុមាលភាពរបស់ប្រជាពលរដ្ឋនៅទូទាំងព្រះរាជាណាចក្រកម្ពុជា ។

មរណភាពរបស់**សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម** គឺជាការបាត់បង់ដ៏ធំធេងរបស់សង្គមជាតិកម្ពុជាទាំងមូល ។ ខ្ញុំជឿជាក់ថា ប្រជាពលរដ្ឋកម្ពុជាគ្រប់រូបនឹងចងចាំជានិច្ចនៅក្នុងក្រអៅបេះដូងនូវគុណូបការៈដ៏ប្រពៃថ្លៃថ្លា ពលិកម្មដ៏ខ្ពង់ខ្ពស់បំផុត និងទឹកចិត្តស្នេហាជាតិដ៏ស្មោះស្ម័គ្ររបស់សម្តេច ចំពោះជាតិមាតុភូមិជាទីស្នេហានៃយើង ដែលនេះគឺជាគំរូវីរភាពដ៏ឧត្តុងឧត្តម ។

ឆ្លៀតក្នុងឱកាសដ៏សែនក្រៀមក្រំនេះ យើងខ្ញុំសូមលំឱនកាយឧទ្ទិសបួងសួងដល់វិញ្ញាណក្ខន្ធរបស់**សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម** បានចាប់បដិសន្ធិក្នុងសុគតិភព កុំបីឃ្លៀងឃ្លាតឡើយ ។

សូមឯកឧត្តម អនុប្រធានទី១នៃព្រឹទ្ធសភា ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីយើងខ្ញុំ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០១៥

**ទេសរដ្ឋមន្ត្រី**
**និង ជាប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍**

អៀង ‿ មូលី